ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២១០២ កសក

រាជធានីភ្នំពេញ, ថ្ងៃទី...០៧...ខែ...មេសា...ឆ្នាំ ២០១៥

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល០៣ខែ ដើមឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបថា នៅក្នុងរយៈពេល០៣ខែ ដើមឆ្នាំ២០១៥នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ National Phytosanitary database (NPD/GDA from 07:00/01.01.2015 to 17:00/31.03.2015) ដែលជាតួលេខនៃការនាំចេញតាមរយៈការរៀបចំវេចខ្ចប់គ្រប់ចំនួន រួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីនាំចេញមានដូចខាងក្រោម ៖

១-ស្ថានភាពនៃការនាំចេញអង្ករក្នុងរយៈពេល០៣ខែ ដើមឆ្នាំ២០១៥ ៖

- បរិមាណអង្ករនាំចេញមានចំនួន១៤៩.៤៦៤តោន មានការកើនឡើងចំនួន៦៥.១៣៤តោន ច្រើនជាងរយៈពេល ៣ខែ ដើមឆ្នាំ២០១៤ ដែលនាំចេញបានតែ៨៤.៣៣០តោន។ ដោយឡែកបរិមាណអង្ករនាំចេញក្នុងរយៈក្នុងខែមីនា ឆ្នាំ២០១៥នេះ មានចំនួន៧៥.៨៦៧តោន ដែលមានការកើនឡើងចំនួន៤០.១១០តោន លើសបរិមាណនាំចេញក្នុងខែមីនាដើមឆ្នាំ២០១៤ ដែលនាំចេញបាន៣៥.៧៥៧តោន (សូមបង្ហាញជូនក្នុងតារាងទី១នៃឧបសម្ព័ន្ធ)

- អង្ករក្រអូបគ្រប់ប្រភេទមានបរិមាណនាំមុខគេដែលមានកំណើនកើនឡើងរហូតដល់៧០.៥៦៩តោន ស្មើនឹង៤៧,២% អង្ករ ស គ្រប់ប្រភេទមានចំនួន៧០.៥៩០តោន ស្មើនឹង៤៧,២%និងអង្ករចំហុយ៨.៣០៥តោន ស្មើនឹង៥,៦%។ ក្នុងចំណោមអង្ករក្រអូបទាំងអស់នោះ អង្ករផ្កាម្លិះ (Jasmine rice) និងផ្ការំដួលមានបរិមាណ៥៣.៤៨៩តោន (លំដាប់ទី១) អង្ករក្រអូបចម្រុះ (សែនក្រអូប នាងសយ និងពួជដទៃ) មាន១១.៣១៣តោន (លំដាប់ទី២) អង្ករក្រអូបនាងម្លិះ៥.២៦៦តោន (លំដាប់ទី៣) និងអង្ករក្រអូបសូមាលី ២៣៩តោន (លំដាប់ទី៤) (សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ)

- អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៤០ប្រទេស (ក្នុងនោះសហភាពអឺរ៉ុប២២ប្រទេស សមាជិកអាស៊ាន២ប្រទេស និងទិសដៅផ្សេងទៀតចំនួន១៦ប្រទេស)។ ក្នុងចំណោមទិសដៅនាំចេញទាំងនោះ ប្រទេសចិនឈរលំដាប់ទី១ (៥៣.៨៧៧តោន) ប្រទេសបារាំងឈរលំដាប់ទី២ (១៨.៨៣៥តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៣ (១៤.៣៣៣តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៤ (១៣.១៩២តោន) ប្រទេសនីឌែរឡែន

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ឈរលំដាប់ទី៥ (១២.១៩០តោន) សាធារណរដ្ឋឆេកឈរលំដាប់ទី៦ (៤.៩៨៩តោន) ប្រទេសបែលហ្សិកលំដាប់ទី៧ (៤.៥៦៩តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៨ (៤.២៦១តោន) ប្រទេសអេស្ប៉ាញឈរលំដាប់ទី៩ (៤.០៧២តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅនៅសហភាពអឺរ៉ុបមានបរិមាណសរុប ៧៤.៧៨៣តោន ស្មើនឹង៥០% ទិសដៅអាស៊ានមានបរិមាណ១៥.៣៥៦តោន ស្មើនឹង១០% និងទិសដៅដទៃផ្សេងទៀតមានបរិមាណ៥៩.៣២៥តោន ស្មើនឹង៤០% នៃបរិមាណនាំចេញសរុប១៤៩.៤៦៤តោន (សូមបង្ហាញជូនក្នុងតារាងទី៣នៃឧបសម្ព័ន្ធ)

- ការនាំចេញមាន៦១ក្រុមហ៊ុន មានកំណើន៨ក្រុមហ៊ុនធៀបនឹងខែកុម្ភៈ ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេដោយៈ (១). ក្រុមហ៊ុន Khmer Food មានចំនួន ២១.៦៧៨តោន (លំដាប់ទី១) (២). ក្រុមហ៊ុន Golden Rice មានចំនួន១៦.៧៦៥តោន (លំដាប់ទី២) (៣).ក្រុមហ៊ុន Amru Rice មានចំនួន១៣.០៥៨តោន (លំដាប់ទី៣) (៤). ក្រុមហ៊ុន BAITANG មានចំនួន៩.៧៥៧តោន (លំដាប់ទី៤) (៥). ក្រុមហ៊ុន International Rice Trading មានចំនួន៧.៨២១តោន (លំដាប់ទី៥) (៦). ក្រុមហ៊ុន HUNG HIEP មានចំនួន៦.៩៩០តោន (លំដាប់ទី៦) (៧). ក្រុមហ៊ុន NICOLINE INVESTMENT មានចំនួន៦.៨១៤តោន (លំដាប់ទី៧) (៨). ក្រុមហ៊ុន T.O.T មានចំនួន៦.៤៧២តោន (លំដាប់ទី៨) (៩). ក្រុមហ៊ុន Mekong Oryza មានចំនួន៥.៧១០តោន (លំដាប់ទី៩) (១០). ក្រុមហ៊ុន GOLDEN DAUN KEO មានចំនួន៥.៣៦៤តោន (លំដាប់ទី១០) សូមបង្ហាញជូនក្នុងតារាងទី៤នៃឧបសម្ព័ន្ធ)។

២- ស្ថានភាពនៃការបំពេញបែបបទសម្រាប់ការនាំចេញអង្ករគឺមានដំណើរការប្រព្រឹត្តទៅដូចខែមុនៗដែរ ជាមួយនឹងការខិតខំប្រឹងប្រែងដើម្បីកែលម្អការបំពេញសេវាឲ្យកាន់តែមានភាពល្អប្រសើរជាងមុន។ សន្ទុះនៃការនាំចេញអង្ករក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៥នេះ ជាសញ្ញាវិជ្ជមានមួយប្រកបដោយក្តីសង្ឃឹមដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធរួមទាំងវិស័យឯកជនផងដែរកំពុងបន្តការខិតខំផ្សព្វផ្សាយដល់គ្រប់ដៃគូទាំងអស់ឱ្យចូលរួមដោះស្រាយរាល់បញ្ហាដែលពាក់ព័ន្ធនឹងសកម្មភាពប្រមូលទិញនិងកែច្នៃអង្ករ ប្រព័ន្ធសកម្មភាពសម្រួលការនាំចេញ និងសកម្មភាពពង្រីកទីផ្សារអង្ករ ដើម្បីជំរុញការនាំចេញអង្ករដែលមានគុណភាពខ្ពស់ និងមធ្យម ឈានទៅសម្រេចជោគជ័យតាមគោលដៅកំណត់របស់រាជរដ្ឋាភិបាលឲ្យបានយ៉ាងតិច១លានតោននៅឆ្នាំ២០១៥។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
"ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ
"ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ក្រុមការងារផ្នែកស្រូវ-អង្ករនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ
WORKING GROUP ON PADDY- RICE OF THE ROYAL GOVERNMENT AND PRIVATE SECTOR FORUM
Secretariat of One Window Service for Rice Export Formality (SOWS-REF)

## ឧបសម្ព័ន្ធ: របាយការណ៍អំពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាប្រចាំខែមីនា ឆ្នាំ២០១៥

## (ANNEX: THE REPORT ON CAMBODIAN RICE EXPORT STATUS IN MARCH, 2015)

(Base on NPD/GDA from 07:00/01.01.2015 to 17:00/31.03.2015 and all number are English punctuation)

### តារាងទី១.បរិមាណអង្ករកម្ពុជាដែលបាននាំចេញប្រចាំខែ ក្នុងឆ្នាំ ២០១១ - ២០១៥, គិតជាតោន

(Table1. Quantity of Cambodian Rice have been Exported by months of 2011-2015, in tones)

| Month/ Year | 2011 | 2012 | 2013 | 2014 | 2015 | VARIATION |
|---|---|---|---|---|---|---|
| 1. មករា (January) | 6,798 | 9,703 | 25,726 | **21,536** | **35,921** | +66.80% |
| 2.កុម្ភៈ (February) | 5,089 | 14,417 | 24,089 | **27,037** | **37,676** | +39.30% |
| 3. មិនា (March) | 12,534 | 12,310 | 45,413 | **35,757** | 75,867 | +112.70% |
| Sub-Total for 3 months | **24,421** | **36,430** | **95,228** | **84,330** | 149,464 | +77.20% |
| 4. មេសា (April) | 17,946 | 15,036 | 23,276 | 35,961 | | |
| 5. ឧសភា ( May) | 20,520 | 13,115 | 28,350 | 27,971 | | |
| 6.មិថុនា (June) | 17,990 | 13,426 | 29,105 | 29,666 | | |
| 7.កក្កដា (July) | 12,703 | 20,527 | 31,411 | 26,060 | | |
| 8. សីហា (August) | 20,404 | 15,530 | 29,358 | 29,871 | | |
| 9. កញ្ញា (September) | 14,384 | 15,169 | 29,395 | 35,511 | | |
| 10. តុលា (October) | 19,067 | 16,967 | 28,031 | 35,418 | | |
| 11. វិច្ឆិកា (November) | 9,559 | 25,189 | 37,855 | 31,137 | | |
| 12. ធ្នូ (December) | 44,905 | 34,328 | 46,847 | 51,136 | | |
| **Total for 12months/year** | **201,899** | 205,717 | 378,856 | 387,061 | | |

### តារាងទី២.ប្រភេទអង្ករកម្ពុជាដែលបាននាំចេញក្នុង៣ខែដើមឆ្នាំ ២០១៥, គិតជាតោន

(Table 2. Type of Cambodian Rice have been Exported in 3 months of 2015, in tones)

| ប្រភេទអង្ករ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | សរុប (TOTAL) | |
|---|---|---|---|---|---|---|---|---|---|
| TYPE OF RICE | | JAN | FEB | MAR | APR | MAY | JUN | MT | % |
| I.អង្ករក្រអូប [FRAGANT (F) & JUSMINE(J) RICE]: | | | | | | | | | |
| 1 | ចម្រុះ (F.SENKRAOB, NEANG SAUY....) | 4,233.0 | 2,662.0 | 4,418.0 | | | | 11,313.0 | |
| 2 | នាងម្លិស (F. NEANG MALIS) | 1,741.0 | 1,692.0 | 1,833.0 | | | | 5,266.0 | |
| 3 | សូមាលី .( F. SOMALY) | 95.0 | 48.0 | 96.0 | | | | 239.0 | |
| 4 | ផ្កាម្លិស/ផ្ការំដួល (J.PHKA MALIS/ RUMDUOL) | 15,160.0 | 13,179.0 | 25,150.0 | | | | 53,489.0 | |
| 5 | សរីរាង្គ (J.ORGANIC) | 24.0 | 20.0 | 170.0 | | | | 214.0 | |
| 6 | ភ្លី . (F. PEARL) | 48.0 | - | - | | | | 48.0 | |
| | SUB-TOTAL | 21,301 | 17,601 | 31,667 | | | | 70,569.0 | **47.2%** |

II. អង្ករស [ WHITE RICE] :

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | ចម្រុះគ្រាប់វែង (LONG GRAIN) | 12,600.0 | 16,786.0 | 39,825.0 | | | | 69,211.0 | |
| 2 | ប្រណិតគ្រាប់វែង (PREMIUM LONG GRAIN) | 712.0 | 314.0 | 353.0 | | | | 1,379.0 | |
| | SUB-TOTAL | 13,312 | 17,100 | 40,178 | | | | 70,590.0 | 47.2% |

III.អង្ករចំហុយ [PABOILLED RICE]:

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | ចំហុយគ្រាប់វែង (LONG GRAIN PABOILLED) | 1,308.0 | 2,975.0 | 4,022.0 | | | | 8,305.0 | |
| | SUB-TOTAL | 1,308 | 2,975 | 4,022 | | | | 8,305.0 | 5.6% |
| | GRAND TOTAL | 35,921.0 | 37,676.0 | 75,867.0 | | | | 149,464.0 | 100% |

# តារាងទី៣.ទិសដៅនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល៣ខែដើមឆ្នាំ ២០១៥, គិតជាតោន

(Table 3. Export Destination of Cambodian Rice in 3 Month of 2015, in tones)

| | ប្រទេសទិសដៅ COUNTRY DESTINATION | មករា JAN | កុម្ភៈ FEB | មីនា MAR | មេសា APR | ឧសភា MAY | មិថុនា JUN | កក្កដា JUL | សីហា AUG | កញ្ញា SEP | តុលា OCT | វិច្ឆិកា NOV | ធ្នូ DEC | សរុប TOTAL |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | **I.សមាជិកសហគមន៍អឺរ៉ុប /EUROPEAN UNION** | | | | | | | | | | | | | |
| 1 | FRANCE | 7,307 | 5,074 | 6,454 | | | | | | | | | | 18,835 |
| 2 | POLAND | 2,608 | 4,266 | 6,318 | | | | | | | | | | 13,192 |
| 3 | NETHERLAND | 4,703 | 3,773 | 3,714 | | | | | | | | | | 12,190 |
| 4 | CZECH REPUBLIC | 1,237 | 1,685 | 2,067 | | | | | | | | | | 4,989 |
| 5 | BELGIUM | 1,181 | 1,565 | 1,823 | | | | | | | | | | 4,569 |
| 6 | UNITED KINGDOM | 1,991 | 672 | 1,598 | | | | | | | | | | 4,261 |
| 7 | SPAIN | 959 | 1,253 | 1,860 | | | | | | | | | | 4,072 |
| 8 | ITALY | 119 | 1,312 | 1,839 | | | | | | | | | | 3,270 |
| 9 | GERMANY | 1,137 | 390 | 626 | | | | | | | | | | 2,153 |
| 10 | PORTUGAL | 556 | 588 | 795 | | | | | | | | | | 1,939 |
| 11 | GREECE | 112 | 96 | 1,545 | | | | | | | | | | 1,753 |
| 12 | SWEEDEN | | 244 | 719 | | | | | | | | | | 963 |
| 13 | ROMANIA | | 240 | 240 | | | | | | | | | | 480 |
| 14 | CROATIA | 50 | 99 | 296 | | | | | | | | | | 445 |
| 15 | DENMARK | 23 | | 389 | | | | | | | | | | 412 |
| 16 | LATIVA | | 125 | 250 | | | | | | | | | | 375 |
| 17 | LITHUANIA | | 300 | 25 | | | | | | | | | | 325 |
| 18 | ESTONIA | | | 200 | | | | | | | | | | 200 |
| 19 | AUSTRIA | 49 | 25 | 96 | | | | | | | | | | 170 |
| 20 | HONGARY | | | 120 | | | | | | | | | | 120 |
| 21 | FINLAND | 48 | | | | | | | | | | | | 48 |
| 22 | CYPRUS | | | 22 | | | | | | | | | | 22 |
| | SUB-TOTAL | 22,080 | 21,707 | 30,996 | | | | | | | | | | 74,783 |
| | **II. សមាជិកអាស៊ាន/ASEAN MEMBER STATE** | | | | | | | | | | | | | |
| 1 | MALAYSIA | 4,002 | 5,478 | 4,853 | | | | | | | | | | 14,333 |
| 2 | SINGAPORE | 233 | 355 | 435 | | | | | | | | | | 1,023 |
| | SUB-TOTAL | 4,235 | 5,833 | 5,288 | | | | | | | | | | 15,356 |
| | **III.ទិសដៅផ្សេងទៀត /OTHERS DESTINATION** | | | | | | | | | | | | | |
| 1 | CHINA | 8,974 | 8,822 | 36,081 | | | | | | | | | | 53,877 |
| 2 | HONG KONG | | 751 | 838 | | | | | | | | | | 1,589 |
| 3 | GABON | | | 1,293 | | | | | | | | | | 1,293 |
| 4 | BELARUS | | 25 | 500 | | | | | | | | | | 525 |
| 5 | AUSTRALIA | 210 | 48 | 193 | | | | | | | | | | 451 |
| 6 | USA | 20 | 116 | 296 | | | | | | | | | | 432 |
| 7 | RUSSIAN FED | 192 | 216 | | | | | | | | | | | 408 |
| 8 | IRAQ | | | 207 | | | | | | | | | | 207 |
| 9 | ISRAEL | 48 | | 78 | | | | | | | | | | 126 |
| 10 | NEW ZEALAND | | 112 | | | | | | | | | | | 112 |
| 11 | TAIWAN | 92 | | | | | | | | | | | | 92 |
| 12 | CANADA | 21 | | 47 | | | | | | | | | | 68 |
| 13 | ANGOLA | 25 | | 25 | | | | | | | | | | 50 |
| 14 | SWITZERLAND | 24 | 21 | | | | | | | | | | | 45 |
| 15 | NAMIBIA | | 25 | | | | | | | | | | | 25 |
| 16 | UKRAINE | | | 25 | | | | | | | | | | 25 |
| | SUB-TOTAL | 9,606 | 10,136 | 39,583 | | | | | | | | | | 59,325 |
| | GRAND TOTAL | 35,921 | 37,676 | 75,867 | | | | | | | | | | 149,464 |

តារាងទី៤.ក្រុមហ៊ុននិងបរិមាណដែលបានធ្វើការនាំចេញអង្ករកម្ពុជា៣ខែដើមឆ្នាំ ២០១៥,គិតជាតោន

(Table 4.Cambodian Rice Exporters and export quantity 3 Months of 2015, in tones)

| No | ក្រុមហ៊ុននាំចេញអង្ករ (Cambodian Rice Exporters) | បរិមាណ (Quantity), tones & % | |
|---|---|---|---|
| 1 | **KHMER FOODS GROUP CO.,LTD.** | **21,678.00** | **14.50%** |
| 2 | **GOLDEN RICE (CAMBODIA) CO.,LTD.** | **16,765.00** | **11.22%** |
| 3 | **AMRU RICE (CAMBODIA) CO.,LTD** | **13,058.00** | **8.74%** |
| 4 | **BAITANG (KAMPUCHEA) PLC.** | **9,757.00** | **6.53%** |
| 5 | **INTERNATIONAL RICE TRADING (CAMBODIA) CO.,LTD.** | **7,821.00** | **5.23%** |
| 6 | **HUNG HIEP (CAMBODIA) CO., LTD** | **6,990.00** | **4.68%** |
| 7 | **NIKOLINE INVESTMENT CO., LTD.** | **6,814.00** | **4.56%** |
| 8 | **T.O.T (TRUST OUR TRADE) CO., LTD.** | **6,472.00** | **4.33%** |
| 9 | **MEKONG ORYZA TRADING CO., LTD.** | **5,710.00** | **3.82%** |
| 10 | **GOLDEN DAUN KEO RICE MILL CO., LTD** | **5,364.00** | **3.59%** |
| 11 | WHITE GOLD IMPORT EXPORT CO,. LTD. | 5,138.00 | 3.44% |
| 12 | LOR EAK HENG SEK MEAS RICE CO., LTD | 5,074.00 | 3.39% |
| 13 | CK RICE TRADING CO., LTD. | 3,770.00 | 2.52% |
| 14 | SSCORP(CAMBODIA) CO.,LTD | 3,619.00 | 2.42% |
| 15 | SIGNATURES OF ASIA CO.,LTD | 3,240.00 | 2.17% |
| 16 | VONG BUNHENG IMPORT EXPORT CO., LTD | 2,919.00 | 1.95% |
| 17 | W.K.R TRADING CO.,LTD | 2,174.00 | 1.45% |
| 18 | GREEN TRAD company | 2,000.00 | 1.34% |
| 19 | BATTAMBANG RICE INVESTMENT CO., LTD | 1,988.00 | 1.33% |
| 20 | LORAN GROUP LPC | 1,977.00 | 1.32% |
| 21 | CPFS INTERTRADE CO., LTD. | 1,807.00 | 1.21% |
| 22 | CITY RICE IMPORT EXPORT CO., LTD. | 1,659.00 | 1.11% |
| 23 | KHY THAY CORPORATION CO.,LTD. | 1,562.00 | 1.05% |
| 24 | INDOCHINA RICE MILL LIMITED | 1,264.00 | 0.85% |
| 25 | ANDURIZ (CAMBODGE) SARL | 1,243.00 | 0.83% |
| 26 | THMOR KORL RICE IMPORT EXPORT CO., LTD | 1,058.00 | 0.71% |
| 27 | BOOST RICHE (CAMBODIA) CO., LTD. | 917.00 | 0.61% |
| 28 | COMMODITY IN FOCUS CO., LTD. | 815.00 | 0.55% |
| 29 | PHOU POY DEVELOPMENT IMPORT EXPORT CO., LTD | 781.00 | 0.52% |
| 30 | CAMBODIAN DIAMOND SEAFOOD&AGRICULTURE CO.,LTD. | 589.00 | 0.39% |
| 31 | Amru and hanwha international co., ltd | 552.00 | 0.37% |
| 32 | C.H.Y.N RICE IMPORT EXPORT CO., LTD | 531.00 | 0.36% |
| 33 | SARY KUNTHEA INTERNATIONAL TRADING CO.,LTD | 500.00 | 0.33% |
| 34 | CRISTAL RICE (Kampuchea) co., ltd. | 441.00 | 0.30% |
| 35 | AROMA RICE IMPORT EXPORT CO.,LTD | 415.00 | 0.28% |
| 36 | ANGKOR KASEKAM ROONGROEUNG CO.,LTD. | 382.00 | 0.26% |
| 37 | DOMNAK TEUK GROUP CO.,LTD | 308.00 | 0.21% |
| 38 | TECH SOON AGRO INDUSTRY CO.,LTD | 300.00 | 0.20% |
| 39 | CAVIFOODS CO., LTD (CAMBODIA VIETNAM FOODS) | 194.00 | 0.13% |
| 40 | OU TONG DEVELOPMENT (CAMBODIA) CO., LTD | 187.00 | 0.13% |
| 41 | CAMBODIAN LI SHINE INTERNATIONAL TRADE CO., LTD | 171.00 | 0.11% |
| 42 | TT MILLER TECH (cambodia) co., ltd. | 120.00 | 0.08% |
| 43 | CARMA RICE LIMITED | 110.00 | 0.07% |
| 44 | SAHAKREAS CEDAC LTD | 109.00 | 0.07% |
| 45 | ANGKOR FOOD NOODLE (CAMBODIA) CO.,LTD | 105.00 | 0.07% |
| 46 | FED RICE BATTAMBANG LTD | 100.00 | 0.07% |
| 47 | LIM HENG LEAP TRADING CO.,LTD | 100.00 | 0.07% |
| 48 | OVERSEAS FOODS IMPORT EXPORT CO.,LTD | 95.00 | 0.06% |

| | | | |
|---|---|---|---|
| 49 | MODERN FOODS (CAMBODIA) CO.,LTD. | 94.00 | 0.06% |
| 50 | GUOHONG (CAMBODIA) INDUSTRY CO.,LTD | 92.00 | 0.06% |
| 51 | Khmer natural rice & food co., ltd | 92.00 | 0.06% |
| 52 | LIM KHEANG HOUT IMPORT EXPORT CO., LTD. | 75.00 | 0.05% |
| 53 | BAYON JASMINE RICE CO., LTD | 72.00 | 0.05% |
| 54 | TESLA INDUSTRIES CO., LTD. | 69.00 | 0.05% |
| 55 | EANG HEANG IMPORT EXPORT CO., LTD | 48.00 | 0.03% |
| 56 | Mufavor international (cambodia) inc. | 42.00 | 0.03% |
| 57 | CAMBODIAN COMMODITIES CONSORTIUM LTD. | 42.00 | 0.03% |
| 58 | BELEKE IMPORT & EXPORT CO., LTD. | 25.00 | 0.02% |
| 59 | GREEAT GRAIN & Garment Asia pacific (Cambodia) co., ltd | 24.00 | 0.02% |
| 60 | SOK KEO IMPORT EXPORT CO.,LTD | 24.00 | 0.02% |
| 61 | MONITA TRADING IMPORT EXPORT CO., LTD. | 22.00 | 0.01% |
| | សរុប (*TOTAL)* | 149,464 | 100% |

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

អ្នករៀបចំសរុបទិន្នន័យ

**ខិន នរិទ្ធ**

**បានឃើញ និង ឯកភាព**

**ប្រធានលេខាធិការដ្ឋាន**

**ច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ**

**បណ្ឌិត ហ៊ាន វណ្ណហាន**